PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
*****

លេខ: ៦៦/២១-PPSEZ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការផ្ទេរភាគហ៊ុនរបស់ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ីទៅឱ្យ ក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)ខូអិលធីឌី

ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី សូមប្រកាសថា ម្ចាស់ភាគហ៊ុននិក និងជាអតីតប្រធានក្រុមប្រឹក្សាភិបាល លោកជំទាវ ឧកញ៉ា លឹម ឈីវហូ ("លោកជំទាវ លឹម") បានប្រគល់ភាគហ៊ុន ១០០% នៃភាគហ៊ុន ៤៥,០៩% ដែលស្មើនឹង ៣២.៤១០.០០០ ភាគហ៊ុននៅក្នុង PPSP ទៅឱ្យក្រុមហ៊ុន Inter Logistics (Cambodia) Co .,Ltd ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Royal Group ។ លោក Eric Tan កូនប្រុសច្បងរបស់លោក លោកជំទាវ លឹម និងជាប្រធានក្រុមប្រឹក្សាភិបាល PPSP មានប្រសាសន៍ថា ក្រុមគ្រួសារបានឆ្លៀតយកឱកាសនេះដើម្បីដកផលប្រយោជន៍របស់ខ្លួននៅក្នុង PPSP ខណៈដែលខ្លួននៅតែបន្តស្វែងរកឱកាស វិនិយោគថ្មីៗនៅកម្ពុជា តាមរយៈ LCH Investment Group Co. Ltd. ផ្តោតលើការអភិវឌ្ឍន៍អចលនទ្រព្យឧស្សាហកម្ម (ដូចជាកំពង់ផែអន្តរជាតិស្ទឹងហាវ និងតំបន់សេដ្ឋកិច្ចពិសេសទំហំ ១.០០០ ហិកតា) និង អាជីវកម្មចែកចាយផលិតផលលំដាប់អន្តរជាតិតាមរយៈក្រុមហ៊ុន Attwood Import and Export Co. Ltd.

ដោយបានចាប់ផ្តើម PPSEZ ក្នុងឆ្នាំ ២០០៦ តាំងពីពេលដែលគ្មានអ្វីសោះក្រៅពីដីទំនេរ លោកជំទាវ លឹម បានក្លាយជាកម្លាំងចលករនៅក្នុងក្រុមហ៊ុនរហូតដល់ចូលនិវត្តន៍នៅឆ្នាំ ២០១៩។ ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល នៅឆ្នាំ ២០១៦ PPSP បានចុះបញ្ជីភាគហ៊ុនរបស់ខ្លួននៅលើទីផ្សារមូលបត្រកម្ពុជា ដោយបានក្លាយជាក្រុមហ៊ុនដំបូងគេ និង ចូល IPO តែមួយគត់ក្នុងប្រទេសកម្ពុជា ដែលមានស្ត្រីជាស្ថាបនិក និងជាប្រធាន។ ឥឡូវនេះ PPSEZ គឺជាផ្ទះសម្រាប់កម្មករជាង ៣២.០០០ ដែលបានទាក់ទាញការវិនិយោគជាង ៧០០ លានដុល្លារពីក្រុមហ៊ុនចម្រុះជាតិសាសន៍ជាង ១០០ រួមមាន Ajinomoto, Coca-Cola; Denso; Mavel Garments និង Minebea ។ ដូចនេះ PPSEZ ត្រូវបានទទួលស្គាល់ជាទូទៅថាជាតំបន់សេដ្ឋកិច្ចពិសេសដែលទទួលបានភាពជោគជ័យបំផុតមួយក្នុងប្រទេសកម្ពុជា។ The Inter Logistics (Cambodia) រួមជាមួយនឹងវិនិយោគិនយុទ្ធសាស្ត្រដែលមានស្រាប់របស់ PPSEZ ដូចជា JWD Group (Thailand) និង Zephyr Co. Ltd. (Japan) នឹងបន្តដឹកនាំ PPSEZ ទៅអនាគតដោយជួយ

PHNOM PENH
SPECIAL ECONOMIC ZONE
COMMITTED TO THE FUTURE

ក្រុមហ៊ុនក្នុងការផ្តល់សេវាកម្មដែលមានតម្លៃបន្ថែមដល់អតិថិជន។ នេះត្រូវបានរំពឹងទុកថាជាមួយនឹងម្ចាស់ភាគហ៊ុនថ្មីក្នុងក្រុមប្រឹក្សាភិបាល ក្រុមហ៊ុននឹងបន្តរីកចម្រើនបន្ថែមទៀត និងកាន់តែរឹងមាំ។

លោក Hiroshi Uematsu នាយកប្រតិបត្តិនៃ PPSEZ បានកត់សម្គាល់ថា លោកសូមថ្លែងអំណរគុណចំពោះលោកជំទាវ លីម ក្នុងនាមតំណាងឱ្យអ្នកពាក់ព័ន្ធទាំងអស់ចំពោះការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់លោកជំទាវ ក្នុងការធ្វើឱ្យ PPSEZ មានមកដូចសព្វថ្ងៃនេះ។ "យើងមានទំនុកចិត្តថា The Inter Logistics (Cambodia) នឹងបន្តកេរ្តិ៍ដំណែលពីការប្តេជ្ញាចិត្ត របស់លោកជំទាវ ដោយអនុញ្ញាតឱ្យក្រុមហ៊ុនបន្តផ្តល់ជូននូវសេវាកម្មប្រកបដោយគុណភាព ដោយបង្កើនការរួបរួមគ្នារវាងក្រុមហ៊ុន Inter Logistics (Cambodia) ក៏ដូចជាអាជីវកម្មរបស់ The Royal Group និងអ្នកវិនិយោគអន្តរជាតិរបស់ PPSP និយោជិត និងដៃគូអាជីវកម្ម"។

ការទិញយកនេះបានទទួលការយល់ព្រមពីនិយតករទីផ្សារមូលបត្រកម្ពុជា (SERC) នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០២១ យោងលើលិខិតអនុម័តលេខ ២០៥០/២១ SERC ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបដោយក្តីអនុគ្រោះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១

**ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី**

**PHNOM PENH SEZ PLC.**
National Road No. 4, Sangkat Kantouk, Khan Posenchey, Phnom Penh, Cambodia
+855 (0)23 729 798 +855 (0)23 729 799 sales@ppsez.com
www.ppsez.com